ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆមាសទី១ ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆមាសទី១នេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ១ ៩៨៣ ០៤៥ហ.ត ស្មើនឹង៧៦,០១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆមាសទី១នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅ របស់រាជរដ្ឋាភិបាលដែលសម្រេចបានគិតត្រឹមឆមាសទី១ ឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែកជាំដុះ

### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ១៤៥ ០០៦ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៨ ៨៩៨ហ.ត ស្មើនឹង០,៤១% និងដោយគ្រឿងយន្តចំនួន ២ ១៣៦ ១០៨ហ.ត ស្មើនឹង៩៩,៥៩%
- ផ្ទៃដីសាបសម្រេចបានចំនួន ៩ ៩៣៩ហ.ត លើសឆ្នាំមុនចំនួន ៣ ៩៨០ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ១ ៩៨៣ ០៤៥ហ.ត ស្មើនឹង៧៦,០១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ១៩១ ០៨១ហ.ត។

### ១.២ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៤៣ ២០២ហ.ត ស្មើនឹង៨០,៤៧% នៃផែនការចំនួន ៥៣ ៦៨៦ហ.ត តិចជាងឆ្នាំមុន ៦៩០ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៦៤៩ ៦៩៦ហ.ត ស្មើនឹង៧៩,២៣% នៃផែនការចំនួន ៨១៩ ៩៨៩ហ.ត លើសឆ្នាំមុន ៤ ១៨៥ហ.ត។

### ១.៣ ការនាំចេញផលិតផលកសិកម្ម

**១.៣.១ ការនាំចេញអង្ករ**

- បរិមាណអង្ករនាំចេញមានចំនួន ២៨០ ៤៥០តោន មានការថយចុះចំនួន ១១៧ ២១០តោន (-២៩,៤៧%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល៦ខែឆ្នាំ២០២០ ដែលមានចំនួន ៣៩៧ ៦៦០តោន

- ការនាំចេញអង្ករក្នុងខែមិថុនា ឆ្នាំ២០២១ មានចំនួន ៤៧ ៤១៩តោន កើនឡើងចំនួន ៥ ៨៥៦តោន (១៤,០៩%) បើធៀបនឹងខែមិថុនា ឆ្នាំ២០២០ ដែលមានចំនួន ៤១ ៥៦៣តោន

- អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២០ប្រទេស មានបរិមាណសរុបចំនួន ៦៧ ១៣៦តោន (ថយចុះចំនួន ៦៨ ៤៤០តោន ស្មើនឹង -៥០,៤៨%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៤៣ ២៩៣តោន (ថយចុះចំនួន ៤ ៦៥៦តោន ស្មើនឹង -៣,១៥%) ទិសដៅអាស៊ានចំនួន ៥ប្រទេស មានបរិមាណសរុបចំនួន ២៧ ១៣៦តោន (ថយចុះចំនួន ២៥ ៨៥១តោន ស្មើនឹង -៤៨,៧៩%) និងទិសដៅដទៃទៀតចំនួន ២១ប្រទេស មានបរិមាណសរុប ៤២ ៨៨៥តោន (ថយចុះចំនួន ១៨ ២៦៣តោន ស្មើនឹង -២៩,៨៧%)

- ក្រុមហ៊ុនបាននាំចេញអង្ករចំនួន ៥៦ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន ១០ មានរហូតដល់ ២០៣ ៨៤៧តោន (៧២,៦៩%) និងក្រុមហ៊ុន៤៦ដទៃទៀតបាននាំចេញត្រឹមតែ ៧៦ ៦០៣តោន (២៧,៣១%)។

**១.៣.២ ការនាំចេញកសិផលផ្សេងៗ**

ក្នុងឆមាសទី១ ឆ្នាំ២០២១ មានបរិមាណៈ

- ដំឡូងមីស្រស់ មានចំនួន ៣៥៨ ៨០០តោន (ថយចុះចំនួន -១១,៧៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៦៥ ០០០តោន និងប្រទេសវៀតណាមចំនួន ២៩៣ ៨០០តោន

- ម្សៅដំឡូងមីមានចំនួន ១៥ ៩០៣,៦៤តោន (កើនឡើងចំនួន ១៥,៩៥%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៤ ១៩១តោន ប្រទេសអ៊ីតាលីចំនួន ៥២,៨៤តោន ប្រទេសណេដឺឡេនចំនួន ១១៤តោន ប្រទេសថៃចំនួន ១ ៣៧៥,៨តោន និងសហរដ្ឋអាមេរិកចំនួន ១៧០តោន

- គ្រាប់ស្វាយចន្ទីមានចំនួន ៨៤៣ ២៤៣,២៦តោន (កើនឡើងចំនួន ៣៣៦,៤៣%) នាំចេញទៅប្រទេសចិនចំនួន ៣ ៥៩០,៨៣តោន ប្រទេសឥណ្ឌាចំនួន ១៧តោន ប្រទេសជប៉ុនចំនួន ៣៣,៤៨តោន ប្រទេសកូរ៉េចំនួន ២,០២តោន ប្រទេសឡាវចំនួន ២តោន ប្រទេសអារ៉ាប់ចំនួន ០,៥១តោន ប្រទេសតូហ្គោចំនួន ០,០១តោន ប្រទេសថៃចំនួន ៣ ១៤៧,៤០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន និងប្រទេសវៀតណាមចំនួន ៨៣៦ ៤៥០តោន

- គ្រាប់ពោតមានចំនួន ១៤០ ៦៦៩,១៣តោន (កើនឡើងចំនួន ១៧៦,៤៤%) នាំចេញទៅប្រទេសបង់ក្លាដេសចំនួន ៤២តោន ប្រទេសកូរ៉េចំនួន ២១តោន កោះតៃវ៉ាន់ចំនួន ៦៧៦,១៣តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន និងប្រទេសវៀតណាមចំនួន ៩៧ ៥៨០តោន

- គ្រាប់សណ្តែកបាយមានចំនួន ១៨ ៥៨០តោន (កើនឡើងចំនួន ៥៨៥,៦៧%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្តែកសៀងមានចំនួន ១៧ ៧៥០,០៤តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសថៃចំនួន ៧ ០៥០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន និងប្រទេសវៀតណាមចំនួន ១០ ៧០០តោន

- ផ្លែចេកស្រស់មានចំនួន ២៣៧ ០៩៩,៥តោន (កើនឡើងចំនួន ៦៨,៦៧%) នាំចេញទៅប្រទេសចិនចំនួន ២១១ ០៧៩តោន ប្រទេសជប៉ុនចំនួន ៤២៦,៦៦តោន ប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន និងប្រទេសវៀតណាមចំនួន ២៥ ១១៣,៣៦តោន

- ផ្លែស្វាយស្រស់មានចំនួន ១៥៩ ៧៧៨,៥៥តោន (កើនឡើងចំនួន ២៤៥,៨៤%) នាំចេញទៅទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសកូរ៉េចំនួន ១២៤,៣៨តោន ប្រទេសគុយវ៉ែតចំនួន ០,០១តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន ប្រទេសថៃចំនួន ២០ ៩៦៩,២៨តោន ប្រទេសវៀតណាមចំនួន ១៣៨ ៤០៦,៦៨តោន និងប្រទេសចិនចំនួន ២១១,២២តោន

- ដូងប្រេងចំនួន ២៤ ៤១៦,៦៩តោន (កើនឡើងចំនួន ៨,៦៦%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ២០ ០១៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ៤ ៤០០តោន

- ម្រេចមានចំនួន ១៤ ៥៦១,៦២តោន (កើនឡើងចំនួន ៣៩៨,៧៦%) នាំចេញទៅប្រទេសប៊ែលហ្ស៊ិកចំនួន ១០,៦៣តោន ប្រទេសកាណាដាចំនួន ០,៥២តោន សាធារណរដ្ឋឆេកចំនួន ៦,១០តោន ប្រទេសបារាំងចំនួន ១៩,០១តោន ប្រទេសអាល្លឺម៉ង់ចំនួន ១៦០,៥៧តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសជប៉ុនចំនួន ២,៥៨តោន ប្រទេសកូរ៉េចំនួន ១,៥៥តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន ប្រទេសរុស្ស៊ីចំនួន ០,៣១តោន ប្រទេសស៊ុយអ៊ែតចំនួន ១,២៩តោន ប្រទេសស្វីសចំនួន ០,៤៨តោន កោះតៃវ៉ាន់ចំនួន ១៥តោន ប្រទេសអង់គ្លេសចំនួន ១,២៤តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន សហរដ្ឋអាមេរិកចំនួន ១,៧៥តោន និងប្រទេសវៀតណាមចំនួន ១៤ ២៩១,៤៩តោន

- បន្លែចម្រុះមានចំនួន ៤៤,៩២តោន (ថយចុះចំនួន -២៨,៥១%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៦៤ ៩០៧,១២តោន (កើនឡើងចំនួន ៨៣,៤៧%) នាំចេញទៅប្រទេសថៃចំនួន ៦៤ ៩០៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ៩០០,២២តោន (ថយចុះចំនួន -២៤,៩៨%) នាំចេញទៅប្រទេសថៃចំនួន ៩០០តោន ប្រទេសប៊ែលហ្សិកចំនួន ០,២១តោន និងប្រទេសកាណាដាចំនួន ០,០១តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ (ខែឧសភា)

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៥១៩ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦៤១ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ២៦ ០៤៨តោន កើនឡើងចំនួន ៩ ១៧០តោន ស្មើនឹង៥៤% ធៀបខែមុន និងកើនឡើងចំនួន ៣៥៥តោន ស្មើនឹង១% ធៀបខែឧសភា ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូសម្រេចបានចំនួន ២៩៦ម៣ កើនឡើងចំនួន ៤៦ម៣ ស្មើនឹង១៨,៤០% ធៀបខែមុន។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់សម្រេចបានចំនួន ២៥ ២៦១តោន កើនឡើងចំនួន ៩ ១៤៦តោន ស្មើនឹង៥៦,៧៥% ធៀបខែមុន និងថយចុះចំនួន ១៨៩តោន ស្មើនឹង១% ធៀបខែឧសភា ឆ្នាំ២០២០

- បរិមាណបញ្ចេញលក់ឈើកៅស៊ូសម្រេចបានចំនួន ២៩៦ម៣ កើនឡើង ៤៦ម៣ ស្មើនឹង១៨,៤០% ធៀបខែមុន។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែឧសភាគឺ១ ៧០៤ដុល្លារ/តោន ថយចុះចំនួន ៧៩ដុល្លារ/តោន ស្មើនឹង៤,៤៣% ធៀបខែមុន និងបានកើនឡើងចំនួន ៥១៤ដុល្លារ/តោន ស្មើនឹង៤៣% ធៀបខែឧសភា ឆ្នាំ២០២០

- តម្លៃលក់ឈើកៅស៊ូមធ្យមក្នុងខែឧសភាគឺ១៦០ដុល្លា/ម៣

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែឧសភាគឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ២០០៛/គ.ក្រ ដល់ ៦ ៣២៥៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ២០០៛/គ.ក្រ ដល់ ៣ ៣៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ ចំនួន ៣០ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 ចំនួន ២៥ផ្ទាំង បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១

- បានចេញសេចក្តីប្រកាសស្តីពី ការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៥កន្លែង មានផ្ទៃដី សរុបទំហំ ៣ ៦១៩,៨៦ហ.ត និងបានយល់ព្រមជាគោលការណ៍លើផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ៣កន្លែងមានផ្ទៃដីសរុបទំហំ ១ ៦៣០ហ.ត

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ៩៥គ្រឿង និងយានយន្តចំនួន ១២៨គ្រឿង ជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន៤ នាក់។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវអំពីបន្លាស់ទី ផលប៉ះពាល់ និងអេកូឡូស៊ីសត្វខ្ទីងក្នុងសហគមន៍ព្រៃឈើវាលកន្សែង ស្ថិតក្នុងឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ

- បានចុះប្រមូលលាមកសត្វដំរីក្នុងដែនជម្រកសត្វព្រៃ (ព្រៃឡង់) ក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែនជម្រកសត្វព្រៃឆែប និងដែនជម្រកសត្វព្រៃព្រះរការ ស្រុកជាំក្សាន្ត និងស្រុកឆែប ខេត្តព្រះវិហារដោយប្រមូលបានសំណាកលាមកដំរីចំនួន ១៤៩សំណាក

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៦៩ច្បាប់ ក្នុងនោះ ៦៧ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង ២ច្បាប់សម្រាប់ការថែរក្សាសត្វឃ្មុំ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ខេត្តកោះកុង កំពត តាកែវ ពោធិ៍សាត់ កណ្តាល សៀមរាប បន្ទាយមានជ័យ កំពង់ចាម ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន និងខេត្តមណ្ឌលគីរី

- បានសហការជាមួយអង្គការ FFI ដើម្បីចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១២គ្រឿង នៅតំបន់ជួរភ្នំក្រវាញ ខេត្តកោះកុង ដោយថតជាប់សត្វដំរីព្រៃចំនួន ២៨ក្បាល ប្រើសចំនួន ១១ក្បាល ឈ្លូសចំនួន ៩ក្បាល ស្វាត្រោសចំនួន ៣២ក្បាល ប្រម៉ាចំនួន ១ក្បាល និងជ្រូកព្រៃចំនួន ៨ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមចំនួន ៨៦ ២៨៩ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦៤៥ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ៤០៦ក្បាល ព្យាបាលចំនួន ១៨៣ក្បាល និងស្តារលទ្ធភាព ជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ២៨៨ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវក្រាលក្រួសក្រហមសរុបប្រវែង ៥ ១១៩ម៉ែត្រ និងកាប់ឆ្ការធ្វើអនាម័យព្រៃបានទំហំ ៥,១៣ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- ជីកប្រឡាយការពារចម្ការគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំប្រវែង២ ០០០ម៉ែត្រ
- បានបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសែនមនោរម្យខេត្តមណ្ឌលគិរីលើផ្ទៃដីទំហំ១០០ហ.ត
- បាននិងកំពុងថែទាំចម្ការឈើសរុប៨២២ហ.ត ក្នុងនោះចម្ការពូជឈើ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៤ហ.ត ចម្ការឈើដាំទំហំ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា ទំហំ៣០ហ.ត ស្ថិតក្នុងខេត្តចំនួន៧
- បានឈូសឆាយសម្អាតដីសម្រាប់ដាំឈើជាចម្ការថ្មីទំហំ១០៥ហ.ត ក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំង
- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៣៨៤ ៤០៧ដើម និងចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលចំនួន ១៥ ០០៤ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ៣៨១ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលចាប់ឃាត់ និងដកហូតមាន ឈើអារចំនួន ៦៩៩ម៣ ផ្ទៃដីព្រៃឈើកាប់រានទំហំ៨៥៥ហ.ត ក្នុងខេត្តរតនគិរី ព្រះសីហនុ ព្រះវិហារ ក្រចេះ សៀមរាប កំពង់ស្ពឺ ព្រៃវែង កំពង់ឆ្នាំង ស្ទឹងត្រែង តាកែវ និងខេត្តកំពង់ធំ ព្រមទាំងវត្ថុតាងអនុផលព្រៃឈើ និងឧបករណ៍ផ្សេងៗទៀត។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៧កន្លែង និងពន្យារសុពលភាពចំនួន ៨កន្លែង

- បានពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ២កន្លែង និងពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ និងរោងសិប្បកម្មកែច្នៃចិញ្ច្រាំកម្ទេចឈើដាំចំនួន ៤កន្លែង

- ក្រុមហ៊ុនចំនួន៧បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសចំនួន ៩៣០ម៣ ជ័រទឹកចំនួន ១៩៦តោន និងចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ៤ ០០០តោន

- ក្រុមហ៊ុនចំនួន៣បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ៩០៦ម៣

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៨មានឈើកែច្នៃចំនួន ៦៥៤ម៣ ចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ៧ ០០០តោន ឫស្សីកែច្នៃចំនួន ៣៩តោន និងជ័រទឹកចំនួន ២២៦តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៤មានបរិមាណឈើកែច្នៃ (MDF, Wood Panel, Dark Red Meranti, Chanfuta, ឈើស្រល់) សរុបចំនួន ១ ៤២៥ម៣ ។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានប្រមូលចំណូលសរុប៤ ៣៣៦ ០៨៣ ៦៥៧រៀល និង១ ៥៣៨ ៦៧១,៦១ដុល្លារ ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្មូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ២៦ករណី។ រាជធានី-ខេត្តចំនួន ២៤ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៩៨ ៩៥៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះផ្សព្វផ្សាយអំពីការទប់ស្កាត់ជំងឺផ្តាសាយបក្សី និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៥។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- ចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន៤។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៧ ៤១៩វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ជំងឺផ្តាសាយបក្សីផ្ទុះ១កន្លែងនៅភូមិព្រែកតាប្រែង ឃុំព្រែងនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ ជំងឺដុំពកស្បែកគោ ក្របី (LSD) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) បានរកឃើញតាមរយៈការលួចនាំជ្រូកចូលពីប្រទេសថៃចំនួន ២ករណី នៅខេត្តបន្ទាយមានជ័យ និងត្រូវមន្ត្រីជំនាញសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធសម្រេចដុតកម្ទេចចោលតាមវិធានការបសុព្យាបាល។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបញ្ចប់ត្រឹមចំនួន ១ ៣១០តោន ស្មើនឹង១១,៩១% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន
- នេសាទគ្រួសារដែននេសាទបានចំនួន ១៣២ ២០០តោន ស្មើនឹង៤៤,០៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៧០០តោន
- នេសាទគ្រួសារតាមវាលស្រែបានចំនួន ២២ ០០០តោន ស្មើនឹង១៥,៧១% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៨ ៧០០តោន។

៥.១.២ នេសាទសមុទ្រ

បានចំនួន ៥៧ ៤០០តោន ស្មើនឹង៤៤,១៥% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២០០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ១៤៤ ៣៤០តោន ស្មើនឹង៣០,០១% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨ ៩៤០តោន

- ការចិញ្ចឹមក្រពើបានចំនួន ៩២ ២០០ក្បាល ស្មើនឹង២៧,៩៤% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៥០ ០៤០ក្បាល

- ការភ្ញាស់កូនត្រីពូជបានចំនួន ៨៤ ៣០០ ០០០កូន ស្មើនឹង៣១,២២% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ៨០០ ០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបបានចំនួន ២៥ ៩១០តោន ស្មើនឹង៣២,៣៩% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១ ៣៤០តោន

- ផលនេសាទសមុទ្របានចំនួន ៦ ១៣០តោន ស្មើនឹង៥១,០៨% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២០តោន

- ការផលិតទឹកត្រីបានចំនួន ៣៤ ៧៥០ ០០០លីត្រ ស្មើនឹង៦៣,១៨% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១ ១៦២ ០០០លីត្រ។

**៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល**

- សំណុំរឿងបទល្មើសជលផលមានចំនួន ១ ២១១ករណី ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២១៧ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ១៤១ករណី និងសមុទ្រចំនួន ៧០ករណី។

**៥.៥ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់នាំចេញចំនួន ១ ៩៤៥តោន ស្មើនឹង២៤,៣១% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨០៥តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៤៧តោន ស្មើនឹង៧,៣៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៨៥តោន។

**៥.៦ ការប្រមូលចំណូលថវិកាសេវាជលផល**

- ចំណូលបានចំនួន ៤២៤ ៩២៦ ១២៨រៀល ស្មើនឹង១១៨,៥០% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបឆមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨៣ ៤៤១ ៧៦៨រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះត្រួតពិនិត្យលើការអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផលផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តកណ្តាល ត្បូងឃ្មុំ តាកែវ ព្រៃវែង និងខេត្តកំពត

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងណែនាំឱ្យកែលម្អ

- ការទទួលពាក្យបណ្តឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតចំនួន ២ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៥៨៩ករណី លើវិស័យព្រៃឈើ១៤០ករណី ជលផល១៣៤ករណី ពេទ្យសត្វ៦៣ករណី កៅស៊ូ៧ករណី កសិ-ឧស្សាហកម្ម៤ករណី ក្សេត្រសាស្ត្រ៤ករណី នីតិកម្ម ១ករណី និងវិស័យផ្សេងៗ២៣៦ករណី

- ការងារចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ២៨លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៣ ៧១៣ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ១ ៤០៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ៦៨៣ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៦២៧ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៥ ៥៥២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ២២៩ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១២៥ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨២៣នាក់ (ស្រី១ ៤១៣នាក់ ស្មើនឹង២៤,២៦%) រួមមាន៖
  - អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៤នាក់ (ស្រី៨២៣នាក់ ស្មើនឹង២៨,២៤%)
  - អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩០៩នាក់ (ស្រី៥៩០នាក់ ស្មើនឹង២០,២៨%)

- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៧០នាក់ (ស្រី២៩នាក់)

- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៧នាក់ (ស្រី៣នាក់) ក្នុងនោះ ដោយសុំលាឈប់ពីការងារចំនួន ៤នាក់ និងមរណភាពចំនួន ៣នាក់

- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៧នាក់ (ស្រី១នាក់) ផ្ទេរចូលក្នុងក្រសួងចំនួន ៤នាក់ និងផ្ទេរផ្ទៃក្នុងក្រសួងចំនួន ៣៩នាក់

- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៣៣នាក់ (ស្រី២០នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៥នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ៤នាក់ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ១៦នាក់ និងច្បាប់ឈប់សម្រាកសម្រាប់ព្យាបាលជំងឺចំនួន ៨នាក់

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ចំនួន ១៥នាក់ (ស្រី៨នាក់)

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលបម្រើការងារវិញចំនួន ៧នាក់ (ស្រី១នាក់)

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៥នាក់ (ស្រី២នាក់)

- រៀបចំសំណើទៅក្រសួងមុខងារសាធារណៈស្តីពីសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការប្រចាំឆ្នាំ២០២១ចំនួន២ ៨៣៦នាក់ (ស្រី៦៤២នាក់) ក្នុងនោះ ថ្នាក់កណ្តាលចំនួន ១ ៤៩៦នាក់ (ស្រី៤០៧នាក់) និងថ្នាក់រាជធានី-ខេត្តចំនួន ១ ៣៤០នាក់ (ស្រី២៣៥នាក់)

- ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៧៩៤នាក់ (ស្រី២០៥នាក់) ក្នុងនោះ៖
  - ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ៧៨២នាក់ (ស្រី២០៣នាក់)
  - ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធអនឡាញ (Online) ចំនួន ៤នាក់។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានចូលរួមប្រជុំ សិក្ខាសាលា បណ្តុះបណ្តាល ពិនិត្យផ្តល់យោបល់ និងសហការសម្របសម្រួលការងារជាមួយបណ្តាអង្គភាព ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការនានា

- បានរៀបចំសុំផ្តល់ធាតុចូលលើសេចក្តីព្រាងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២១-២០៣០

- បានរៀបចំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំឆ្នាំ២០២០ ក្នុងការអនុវត្តក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រព័ន្ធអង្គការសហប្រជាជាតិឆ្នាំ២០១៩-២០២៣

- ចុះពង្រឹងលើការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តរតនគិរី ស្ទឹងត្រែង សៀមរាប ឧត្តរមានជ័យ ពោធិ៍សាត់ បន្ទាយមានជ័យ និងខេត្តបាត់ដំបង

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល ២០២២-២០២៤

- បានពិនិត្យ និងកែសម្រួលផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ២០២២-២០២៤

- បានធ្វើការណែនាំ និងធ្វើការអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្តស្រុក បានចុះបេសកកម្មនៅខេត្តពោធិ៍សាត់ ខេត្តក្រចេះ ខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍នូវរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានីខេត្តចំនួន២៥

- បានរៀបចំសំណើផ្តល់កិច្ចសហការ និងសម្របសម្រួលដល់ក្រុមការងារចុះតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២១ និងសុំចាត់មន្ត្រីជំនាញចូលរួមអនុវត្តផ្ទាល់លើការងារតាមដាន និងវាយតម្លៃ

- បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូល និងចុះក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៣៦ ៨២៣ ៩៩៦ ៤១៥រៀល ស្មើនឹង១០៣,៩% ធៀបច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១

- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៤៨ ៦៩៥ ៣៩០ ០៤០រៀល ស្មើនឹង៣២,៦% ធៀបឥណទានថ្មីក្រោយនិយ័តកម្ម

- បានរៀបចំសំណើសុំថវិកាចំនួន ៤១ ២៩១,២៥ដុល្លារអាមេរិក និងចំនួន ២៥ ៦២០អឺរ៉ូ សម្រាប់ទូទាត់ជូនក្រុមហ៊ុន Agriconsulting Europe S.A (AESA) ក្នុងការអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish Aquaculture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)

- បានរៀបចំសំណើសុំថវិកាចំនួន ១៥២ ៨៦១,០៣ដុល្លារអាមេរិក ដើម្បីបំពេញឡើងវិញចូលគណនីគម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គក្រោមហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

- បានទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ១៥ក្រុមហ៊ុន

- បានចុះបំពេញការងារនៅខេត្តព្រៃវែង កំពង់ចាម និងខេត្តកំពង់ឆ្នាំង ដើម្បីពិនិត្យការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្ម

- បានចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តសៀមរាប ចំនួន ៨ក្រុមហ៊ុន

- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ៥៤ក្រុមហ៊ុន

- បានរៀបចំឯកសារសម្រាប់ដំណាក់កាលនៃការរៀបចំដេញថ្លៃ និងចរចាថ្លៃសរុបចំនួន ៦គម្រោង

- បានចូលរួមដេញថ្លៃ និងពិគ្រោះថ្លៃផលឈើដាំនៅសង្កាត់រដ្ឋបាលព្រៃឈើឆ្លូង ផ្នែករដ្ឋបាលព្រៃឈើឆ្លូងនៃខណ្ឌរដ្ឋបាលព្រៃឈើខេត្តក្រចេះ

- បានចូលរួមប្រជុំ ពិនិត្យ និងវាយតម្លៃលក់ផលឈើដាំក្នុងទីតាំងដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង

- បានចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី ឧត្តរមានជ័យ ត្បូងឃ្មុំ ក្រចេះ កំពង់ធំ កំពត និងខេត្តកំពង់ស្ពឺ ស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២២-២០២៤

- បានធ្វើវិចារណកម្មចំណាយលើឥណទានអនុម័តឆ្នាំ២០២១

- បានធ្វើវិចារណកម្មចំណាយលើឥណទានរជ្ជទេយ្យបុរេប្រទានកម្មវិធីឆ្នាំ២០២១

- ពុំបានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ដោយសារស្ថានភាពឆ្លងរាលដាលនៃជំងឺកូវីដ-19។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំ៣លើក សិក្ខាសាលា១លើក ចុះកិច្ចព្រមព្រៀង១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី
- បានចូលរួមកិច្ចប្រជុំ១៨លើក (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ទស្សនកិច្ច១លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស និងកិច្ចប្រជុំ៣លើក ក្រោមក្របខ័ណ្ឌកសិ-ពាណិជ្ជកម្មពិភពលោក
- បានសម្របសម្រួលកិច្ចប្រជុំចំនួន ១២លើក ទស្សនកិច្ច SNV ១លើកលើការងារក្នុងប្រទេស
- បានសម្របសម្រួលកិច្ចការងារជាមួយដៃគូអភិវឌ្ឍន៍ចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងចំនួន ៤គម្រោងដោយគិតជាទឹកប្រាក់ចំនួន ៥ ៨២១ ៨៣៨ដុល្លារ
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយគម្រោង ACIAR-CROP/2019/145 ស្តីពីបច្ចេកទេសគ្រប់គ្រងស្មៅសម្រាប់ប្រព័ន្ធដាំដុះដំណាំនៅវាលទំនាបដោយម៉ាស៊ីននៅប្រទេសកម្ពុជា និងប្រទេសឡាវ
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គភាព WCPO ស្តីពីការពង្រីកការអភិរក្ស និងការពារសុខភាពសត្វព្រៃនៅប្រទេសកម្ពុជា
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គភាព APAARI ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់ការស្រាវជ្រាវកសិកម្មនវានុវត្តន៍ និងការអប់រំកសិកម្មក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៤៦ក្រុមហ៊ុន សរុបចំនួន ១ ៧២៥មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៣២ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤០ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៤៥ក្រុមហ៊ុន សរុបចំនួន ២២៨សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានពិនិត្យលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ៦ករណី
- បានពិនិត្យ និងផ្តល់មតិសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ៥ករណី។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥៧ក្រុមហ៊ុន
- ចុះពិនិត្យការស្នើសុំចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ២២ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- បានដាក់ឲ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ
- បានបង្កើត Sub Domain (dal.maff.gov.kh) របស់នាយកដ្ឋាននីតិកម្មកសិកម្មសម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធ QR Code នៃព័ត៌មានផលិតផលថ្នាំកសិកម្មដែលបានចុះបញ្ជី
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រផុសសរុបចំនួន ១ ៨៣៥ព័ត៌មាន

- ដំឡើង និងកំពុងត្រួតពិនិត្យលើការប្រើប្រាស់ Network Attach Server (NAS) សម្រាប់មជ្ឈមណ្ឌលប្រើប្រាស់ក្នុងការទុកដាក់ឯកសារ

- បណ្ណាល័យកសិកម្មបានទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្ដីទទួលបានពីនាយកដ្ឋានកិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១៦៧ក្បាល/ច្បាប់

- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកមានអ្នកចូលអានចំនួន ៧១ ២៥២ដង/នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្ដីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នៅខេត្តបន្ទាយមានជ័យ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្ដីពីការជោគជ័យលើមុខរបរចិញ្ចឹមឃ្មុំនៅខេត្តត្បូងឃ្មុំ និងមុខរបរបង្កាត់ពូជមាន់ស្រែលក់ ភ្ញាស់កូនមាន់លក់របស់កសិករនៅខេត្តកណ្ដាល

- បានចុះទៅថត Video បទយកការណ៍ចំនួន ១០ប្រធានបទ

- បានចាក់ផ្សាយឡើងវិញស្ដីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ៦ប្រធានបទ

- បានចាក់ផ្សាយឡើងវិញស្ដីពីនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៣៥ដើម្បីចាក់ផ្សាយ

- បានបោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានកសិកម្មស្ដីពីបទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមបង្កង និងភ្ញាស់កូនបង្កងលក់ចំនួន ១ ០០០ច្បាប់។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមក្នុងសិក្ខាសាលាចាប់ផ្ដើមអនុវត្ត និងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីគម្រោងបន្លែ ផ្លែឈើកម្ពុជាដំណាក់កាលទី៣

- បានចូលរួមកិច្ចប្រជុំស្ដីពីការពិនិត្យ និងផ្ដល់ធាតុចូលលើក្របខ័ណ្ឌជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មកម្ពុជា

- បានចូលរួមវគ្គបណ្ដុះបណ្ដាលមន្ទីរពិសោធន៍និម្មិតតាមប្រព័ន្ធ online ស្ដីពីការប្រមូលសំណាកការរៀបចំប្រើប្រាស់ទុកដាក់សំណាក ការលាងសម្អាត និងការវិភាគកាកសំណល់ថ្នាំកសិកម្ម និងការធ្វើបង្ហាញក្នុងមន្ទីរពិសោធន៍តាមវីដេអូ

- បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងគុណភាពចំណីអាហារតាមប្រព័ន្ធ online នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី

- បានចុះជាមួយអ្នកជំនាញការ JICA ពិនិត្យ និងសិក្សាបញ្ហាពាក់ព័ន្ធខ្សែច្រវាក់ផលិតកម្មស្វាយចន្ទីរបស់សហ-គមន៍កសិកម្មស្នើសុំគម្រោង KUSANONE នៃរដ្ឋាភិបាលជប៉ុន នៅខេត្តកំពង់ធំ

- បានចុះបណ្ដុះបណ្ដាលបច្ចេកទេសគ្រប់គ្រងគុណភាព និងសុវត្ថិភាពក្រោយប្រមូលផលនេសាទសមុទ្រនៅខេត្តព្រះសីហនុ

- បានចុះបណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពបុគ្គលិករោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី ជ័យ សំបូរ នៅខេត្តកំពង់ធំអំពីប្រព័ន្ធ HACCP ការប្រើប្រាស់ឧបករណ៍ សម្ភារ និងគ្រឿងម៉ាស៊ីន

- បានធ្វើការវិភាគលើសំណាកត្រីទឹកសាបចំនួន ១៤ប្រភេទ ក្នុងនោះ វិភាគរកកាកសំណល់លោហៈធ្ងន់គឺ អាសេនិច (Arsenic, As) សំណ (Lead, Pb) និងបារត (Mercury, Hg) វិភាគរកសមាសធាតុគីមីគឺ ខ្លាញ់សរុប (Crude Fat) ហ៊ីស្ដាមីន (Histamine) វិភាគរកវត្តមានបាក់តេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)

- បានវិភាគសំណាកទឹកឃ្មុំចំនួន ២ប្រភេទ ក្នុងនោះ វិភាគសមាសធាតុគីមីគឺ សំណើម (Moisture) ផេះ (Ash) អាស៊ីត (Acid/pH) វិភាគរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) មេតំបែ និងផ្សិត (yeast and mold) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)

- បានវិភាគសំណាក ម្សៅត្រីចំនួន ២ប្រភេទ និងចំណីត្រីចំនួន ១ប្រភេទ ក្នុងនោះ វិភាគរកកាកសំណល់លោហៈធ្ងន់អាសេនិច (Arsenic) វិភាគសមាសធាតុគីមីគឺ សំណើម (Moisture) ផេះ (Ash) ប្រូតេអ៊ីន (Crude protein) អាស៊ូត( Nitrogen) ខ្លាញ់សរុប (Crude fat) អំបិល (Salt) ស្ករសរុប(Total sugar) សូដ្យូម(Na) កាល់ស្យូម (Ca) ផូស្វ័រ (P) វិភាគរកវត្តមានបាតេរីបង្កគ្រោះថ្នាក់គឺ បាក់តេរីសរុប (Total Plate count) មេតំបែ និងផ្សិត (yeast and mold) សាល់ម៉ូណេឡា (Salmonella) និងអ៊ីកូលី (E-coli)។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតចំនួន ១៥ប្រភេទ សរុបចំនួន ១០៦សំណាក (ត្រសក់២៨សំណាក ល្ពៅ៣៤សំណាក ឪឡឹក២សំណាក ត្រប់៤សំណាក ម្ទេស២សំណាក ចេក៥សំណាក អំពៅ៦សំណាក ដំឡូងជ្វា ៩សំណាក ដំឡូងឈាមមាន់២សំណាក ដំឡូងដៃខ្លា១សំណាក ត្រាវ១សំណាក សណ្តែក១សំណាក ពោត១សំណាក ស្វាយ៥សំណាក និងស្វាយចន្ទី៥សំណាក) មករក្សាទុកក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៩ប្រភេទ រួមមានស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ២ ៥១៧បញ្ជីក/សំណាក សរុបទាំងអស់ចំនួន ៩ ២៩៣បញ្ជីក/សំណាក។ ដាំវាយតម្លៃ និងកំណត់លក្ខណៈលើដំណាំ៤មុខគឺ មេឡុងចំនួន ៥០សំណាក ម្ទេសចំនួន ៥០សំណាក ល្ពៅចំនួន ៣០សំណាក និងត្រប់ចំនួន ៤០សំណាក

- បានធ្វើពិសោធន៍ចំនួន ៤៥ប្រភេទនៅ១៤៦កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៧០កន្លែង។ បើកវគ្គបណ្តុះបណ្តាលកសិករចំនួន ១២លើកមានកសិករចូលរួមចំនួន ៤០០នាក់

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន ១០លើក មានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន ៦០នាក់ (ស្រី១៤នាក់)។ មន្ត្រីសរុបចំនួន៤នាក់បាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន២នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន២នាក់ នៅប្រទេសកូរ៉េ ជប៉ុន និងប្រទេសចិន

- ក្នុងឆមាសទី១ ឆ្នាំ២០២១នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៧៦៩ ៣០៤នាក់ ហើយគិតជាមធ្យមមានប្រមាណ៥ ១២៨នាក់/ថ្ងៃ

- បានចូលរួមប្រជុំ សន្និបាត និងកិច្ចប្រជុំផ្សេងៗទៀតនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ២៥លើក និងស្ថាប័ន/អង្គភាពនានាចំនួន ១២លើកតាមប្រព័ន្ធ online (ZOOM) និងទទួលជួបភ្ញៀវជាតិនិងអន្តរជាតិនៅវិទ្យាស្ថានចំនួន ៥លើក មានភ្ញៀវសរុប ២២នាក់។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- បានចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាក្រុមដើម្បីជំរុញសុវត្ថិភាពចំណីអាហារតាមរយៈដៃគូរៀបចំដោយគម្រោង CapFish របស់អង្គការ UNIDO

- បានចុះ MOU រវាងមហាវិទ្យាល័យវិស្វកម្មកសិកម្ម និងខ្មែរអេកូតិចណូឡូជី

- បានប្រជុំពិភាក្សាលើសេចក្តីព្រាងចុះ MoU រវាងមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ(BTIC) និង Cambodia Post Bank លើការជំរុញជីវឧស្ម័នខ្នាតធំដោយមានការជួយសម្របសម្រួលពី UNIDO

- បានចូលរួមប្រជុំជាមួយ IFAD Supervision Mission ដើម្បីពិភាក្សាលើការអភិវឌ្ឍមុខវិជ្ជាបច្ចេកវិទ្យាថាមពលកកើតឡើងវិញ

- បានចូលរួមប្រជុំអំពីវិធីសាស្ត្របង្រៀនតាមបែបថ្មីដែលសហការរៀបចំដោយសាកលវិទ្យាល័យហុងកុង និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បានជួបប្រជុំជាមួយតំណាងក្រុមហ៊ុន Solar Green Energy (Cambodia) Co. LTD ដើម្បីស្នើសុំនិស្សិតសហការស្រាវជ្រាវពី Innovation on aquaculture using solar power for freshwater prawn culture in plastic/concrete tanks Auto-motors by using solar power and Auto-water quality management by using solar power

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី Food Safety and Good Hygiene Practices for Entrepreneurs ដល់ក្រុមអ្នកកែច្នៃគ្រាប់ស្វាយចន្ទីតាមរយៈ online

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី Food Industry Virtual Office Hours ក្រោមប្រធានបទសេចក្តីណែនាំសុវត្ថិភាព និងអនាម័យអាហារសម្រាប់ការពារកូវីដ-១៩ ក្នុងឧស្សាហកម្មអាហារតាមរយៈ online

- រៀបចំចុះកិច្ចសន្យាលើសម្ភារវះកាត់របស់មន្ទីរពេទ្យសត្វក្រោមគម្រោង Capacity development of the faculty of veterinary medicine of the royal university of agriculture (RUA) improving veterinary teaching hospital with focus on small animal research and services គាំទ្រដោយ CE SAIN សម្រេចបាន១០០ភាគរយ

- សាស្ត្រាចារ្យ និងនិស្សិតនៃមហាវិទ្យាល័យនីមួយៗ បាននិងកំពុងបន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវលើប្រធានបទរៀងៗខ្លួននៅក្នុងសាកលវិទ្យាល័យ និងនៅមូលដ្ឋានផលិតកម្មផ្សេងៗ។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- និស្សិតនៅប្រទេសអ៊ីស្រាអែលចំនួន ៤១នាក់ (ស្រី២២នាក់) និងនិស្សិតចំនួន ២២ (ស្រី២នាក់) បានវិលត្រឡប់មកកម្ពុជាវិញហើយ

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធន៍ចិញ្ចឹមគោទឹកដោះ ការពិសោធន៍ចិញ្ចឹមបង្គា ការពិសោធន៍បង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធន៍ចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល ការពិសោធន៍ដំណាំព្រីង ការសិក្សាពិសោធន៍ផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធន៍ចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធន៍ចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវាក់តម្លៃស្វាយចន្ទី

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវអេពីដេមីសាស្ត្រ

- ចូលរួមវគ្គបណ្តុះបណ្តាលដើម្បីចែករំលែកបទពិសោធន៍លើការងារស្រាវជ្រាវស្តីជីវសុវត្ថិភាពជំងឺហប្លូណ្ឌូស ជំងឺសត្វឆ្លងដែន និងការគ្រប់គ្រងកាកសំណល់រឹង និងរាវ

- បានទៅខេត្តកំពង់ឆ្នាំងដើម្បីសិក្សាស្រាវជ្រាវពីវត្ថុធាតុដើមសម្រាប់ផលិត និងការប្រើប្រាស់ថ្នាំពុលកសិកម្មធម្មជាតិ

- បានចុះពិនិត្យស្ថានភាពមេគោដើម្បីបង្កាត់សិប្បនិម្មិត និងស្ថានភាពទូទៅនៅស្ថានីយពិសោធន៍កសិកម្មត្រាំកក់ខេត្តតាកែវ២លើក

- បានទៅកាន់ខេត្តព្រៃវែងដើម្បីពិនិត្យការពិសោធន៍ដំណាំស្រូវពូជនាំចូលពីប្រទេសជប៉ុន ដែលអនុវត្តគម្រោងដោយដៃគូអភិវឌ្ឍន៍របស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៥៨៨នាក់ (ស្រី២៦៨នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្មៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច

- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរីនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- តាមដានស្រង់ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយចំនួន ១៧ចម្ការពិសោធន៍

- សហការជាមួយអង្គការ WWF-កម្ពុជា ក្នុងការរៀបចំចម្ការបង្ហាញអំពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ និងចម្ការបង្ហាញអំពីការកែលម្អបច្ចេកទេសលើការយកផលទឹកជ័ររបស់កៅស៊ូគ្រួសារ នៅខេត្តមណ្ឌលគិរី

- តាមដានស្រង់បញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន១៣ និងក្រៅស្ថានីយចំនួន១

- រៀបចំបង្កើតចម្ការពិសោធន៍ឥទ្ធិពលនៃការបើកមុខចៀរនៅទំហំដើមខុសៗគ្នា

- បណ្តុះបណ្តាលមន្ត្រីក្នុងការរៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose (Suc) និង Thiol (R-SH)

- យកសំណាក និងវិភាគ (LD) ចម្ការពិសោធន៍ការប្តូរផ្ទាំងចៀរចំនួន១ ស្មើនឹង២០សំណាក

- បាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបនៅតាមប្រគៀបមែកកៅស៊ូចាប់ពីអាយុ៣ឆ្នាំ ដល់ ១០ឆ្នាំ លើផ្ទៃដី១៦១,៦៦ហ.ត

- វិភាគ pH ដី ចំនួន ១៨០សំណាក

- ត្រួតពិនិត្យការប្រមូលផលជ័រកៅស៊ូ និងការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ

- ធ្វើតេស្ត និងចេញលទ្ធផលតេស្តដល់រោងចក្រកៅស៊ូសន្លឹកចំនួន ៤២សំណាក

- វិភាគកៅស៊ូដុំ (TSR) របស់ក្រុមហ៊ុន អិមអរធី រ៉ាប់ប៊ើ ផ្លេនថេសិនសរុបចំនួន ៣សំណាក

- វិភាគកៅស៊ូដុំ (CSR) របស់ក្រុមហ៊ុន ខេម អេហ្គ្រី រ៉ាប់ប៊ើរ ឯ.ក (ខេត្តព្រះវិហារ) សរុបចំនួន ១០សំណាក។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ១ ៩៨៣ ០៤៥ហ.ត ស្មើនឹង៧៦,០១% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០២១

- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

**២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ**

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

**៣ ផ្នែកព្រៃឈើ**

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កធ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការ

បណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃអង្គារ ១២រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**